# បុរស២នាក់ដណ្ដើមតាំងយូគ្នា

មាននិទានមួយថា : មានបុរសមួយបាំងតាំងយូដើរទៅតាមផ្លូវ ។ មានបុរសមួយទៀតដើរមកជួបនិយាយទៅកាន់ម្ចាស់តាំងយូថា “អ្នកអើយ ! ថ្ងៃក្ដៅណាស់អ្នកឲ្យខ្ញុំដើរដោយសារម្លប់តាំងយូផង បានឬទេ ?” ។ ថៅម្ចាស់តាំងយូឆ្លើយថា “ចូរអ្នកមកដើរផងគ្នាចុះ” ។ ទើបថៅនោះដើរចូលមកក្រោមម្លប់តាំងយូហើយថា “អ្នកអើយ! ឲ្យមកខ្ញុំកាន់ឲ្យអ្នក” ។ ថៅម្ចាស់តាំងយូក៏ឲ្យតាំងយូទៅថៅនោះកាន់ហើយដើរទៅផងគ្នា លុះដល់ផ្លូវបែកដើរបែកចេញទីទៃពីគ្នា ។ ឯថៅម្ចាស់តាំងយូមុននឹងដើរទីទៃពីគ្នានិយាយថា “ចូរឲ្យតាំងយូមកអញវិញ” ។ ថៅនោះថា “ អញនឹងឲ្យតាំងយូអញទៅថៅម្ដេចបាន បើតាំងយូជារបស់អញកាន់ពីផ្ទះអញមក ” ។ ថៅម្ចាស់តាំងយូនោះខឹង ហើយដណ្ដើមតាំងយូអំពីថៅនោះអស់ចិត្តពុំបានឡើយ ទើបថៅទាំង ២ នាក់នាំគ្នាទៅដល់ថៅក្រម ហើយក៏ប្ដឹងដោយដំណើរទីទៃ ៗ ថៅ ១ ឆ្លើយថា “តាំងយូខ្ញុំកាន់អំពីផ្ទះខ្ញុំមក ថៅនោះមកដណ្ដើមតាំងយូនេះពីខ្ញុំ” ។ ឯម្ចាស់តាំងយូឆ្លើយថា “របស់ខ្ញុំៗកាន់ដើរមកពីផ្ទះ ថៅនេះដើរមកជួបនឹងខ្ញុំ បានសុំដើរដោយសារម្លប់តាំងយូខ្ញុំ ហើយយកតាំងយូពីខ្ញុំទៅកាន់ លុះដល់ផ្លូវបែក មុននឹងដើរបែកចេញពីគ្នា ខ្ញុំយកតាំងយូខ្ញុំវិញ ថៅនេះពុំឲ្យខ្ញុំឡើយ ទើបខ្ញុំទាំង ២ នាំគ្នាមកប្ដឹងលោកម្ចាស់សូមលោកពិចារណាក្ដីនេះឲ្យយើងខ្ញុំហោង” ។ ថៅក្រមកាត់ក្ដីនេះពុំបាន ទើបនាំថៅទាំង ២ នេះឡើងក្រាបបង្គំទូលព្រះមហាក្សត្រដោយនូវដំណើរនោះសព្វគ្រប់ ។ ព្រះមហាក្សត្រទ្រង់ព្រះចិន្ដាពិចារណាឈ្វេងយល់ ដោយនូវប្រាជ្ញាទិព្វវិសេស ក៏ទ្រង់ឲ្យពុះតាំងយូនោះ ចែកគ្នា ១ ចំហៀងម្នាក់ ហើយទើបព្រះអង្គឲ្យទៅផ្ទះទីទៃ ៗ រួចទ្រង់ឲ្យអាមាត្យ ទៅតាមស្ដាប់ពាក្យសម្ដីថៅទាំង ២ នោះដល់ផ្ទះរៀងខ្លួន ។ ឯបុរសម្ចាស់តាំងយូកាលបើទៅដល់ផ្ទះប្រពន្ធស្រែកសួរថា “ តាំងយូបាត់ទៅណាមួយចំហៀង ? ” ។ ប្ដីឆ្លើយថា “ មេអើយ ! អញដើរទៅជួបនឹងថៅម្នាក់មកដោយសារម្លប់តាំងយូអញ ហើយវាយកទៅកាន់ដើរផងគ្នា ទៅដល់ផ្លូវបែក មុននឹងបែកទៅតាមផ្លូវទីទៃពីគ្នា អញយកតាំងយូវិញ វាពុំឲ្យ ទើបនាំគ្នាទៅគាល់ព្រះមហាក្សត្រ ៗ ទ្រង់បង្គាប់ឲ្យពុះតាំងយូនេះចែកគ្នា ” ។ អាមាត្យឮពាក្យប្រពន្ធបុរសម្ចាស់តាំងយូសួរ ហើយប្ដីប្រាប់ប្រពន្ធដូច្នោះ ក៏កត់ពាក្យនោះនាំមកថ្វាយព្រះមហាក្សត្រ ។ បុរសម្នាក់ទៀត ដើរទៅដល់ផ្ទះប្រពន្ធស្រែកសួរថា “ យើ ! បានតាំងយូ ១ ចំហៀងមកពីណា ? ” ។ ប្ដីប្រាប់ទៅប្រពន្ធថា “ ឯងអើយ ! អញដើរទៅលេង ៗ បានតាំងយូ ១ ចំហៀងព្រងើយ ” ។ អាមាត្យបានឮពាក្យបុរសនោះនិយាយ ហើយបានកត់ត្រាពាក្យនោះនាំថ្វាយព្រះមហាក្សត្រ ៗ ទ្រង់ឲ្យហៅថៅទាំង ២ នោះមកដល់ហើយ ទើបទ្រង់ឲ្យសូត្រតម្រាពាក្យនោះឲ្យថៅទាំង ២ ស្ដាប់ ។ ថៅដែលដណ្ដើមតាំងយូនោះ យល់ថាខ្លួនខុសពិតហើយ ក៏ឥតចម្លើយអ្វីនឹងឆ្លើយឡើយឱនមុខអៀនអន់ស្ងាត់បាត់មាត់នៅទីនោះ ។ ទើបព្រះមហាក្សត្រទ្រង់ព្រះរាជបញ្ជាឲ្យបុរសនោះសងតាំងយូគេ ។ ព្រះមហាក្សត្រទ្រង់ព្រះរាជបញ្ជាដូច្នេះ ថៅទាំង ២ នោះចូលចិត្តហើយ ក៏ក្រាបបង្គំលាទៅលំនៅទីទៃៗ ហោង ។